# ការណែនាំអំពីការដំឡើង
# DRC-004G



# I. សេចក្តីផ្តើម

DRC-004G ជាឧបករណ៍ត្រួតពិនិត្យ និងតាមដានព័ត៌មាន នាឡិកាស្ទង់ថាមពលអគ្គិសនីពីចម្ងាយ Landis +Gyr ។ DRC-004G មានសមត្ថភាពក្នុងការត្រួតពិនិត្យតាមដានទិន្នន័យ ថាមពល ចរន្ត តង់ស្យុង កត្តាអានុភាព ប្រេកង់ របស់បណ្តាញ អគ្គិសនី ។ តាមរយៈការបំពាក់ DRC-004G ជាមួយនាឡិកា វាស់ស្ទង់ថាមពលអគ្គិសនី នឹងធ្វើឲ្យអ្នកផ្គត់ផ្គង់អគ្គិសនីទទួល បានផលចំណេញជាច្រើន និងកាត់បន្ថយទៅលើការចំណាយរបស់ ប្រតិបត្តិការអាជីវកម្មនានា មានដូចជា៖ កាត់បន្ថយកម្លាំងពលកម្ម ក្នុងការចុះស្រង់អំណានតាមទីតាំងនាឡិកាវាស់ស្ទង់ និងរយៈពេល ក្នុងការចុះស្រង់ថាមពលប្រើប្រាស់ប្រចាំខែ និងចំណាយផ្សេងៗ ទៀត ដោយគ្រាន់តែប្រើប្រាស់កម្មវិធីទូរស័ព្ទដៃស្មាតហ្វូន និង កម្មវិធីកុំព្យូទ័រ (DRS) ។

# II. គ្រឿងបរិក្ខារ



ឧបករណ៍ត្រួតពិនិត្យនាឡិកាវាស់ស្ទង់ថាមពលអគ្គិសនីពីចម្ងាយ DRC-004G ចំនួន ១



ជើងទម្រឧបករណ៍ត្រួតពិនិត្យនាឡិកាវាស់ស្ទង់ថាមពលអគ្គិសនីពីចម្ងាយ DRC-004G ចំនួន ១



អង់តែន GSM ចំនួន ១



ឧបករណ៍ទាញយកទិន្នន័យ (Infrared) ចំនួន ១



ឧបករណ៍ការពារពន្លឺរបស់ឧបករណ៍ទាញយកទិន្នន័យ (Infrared) ចំនួន ១



ខ្សែភ្លើងចរន្តឆ្លាស់ ចំនួន ១



ឧបករណ៍ចាប់សញ្ញាបើកទ្វា ចំនួន ១



ជើងទម្រឧបករណ៍ចាប់សញ្ញាបើកទ្វាចំនួន ១



ខ្សែចំណងជ័រ ចំនួន ៤



គ្រាប់មិន ចំនួន ៤



វីស ចំនួន ២

# III. ការដំឡើង

## សម្ភារសម្រាប់ដំឡើង



អូមម៉ែត្រ



ទួណឺវីសមុខ ៤



ដង្កាប់បាញ់គ្រាប់មិន



ដង្កាប់កាត់ខ្សែភ្លើង

# ដំណើរការដំឡើង DRC-004G

**01** បំពាក់ជើងទម្រឧបករណ៍ត្រួតពិនិត្យនាឡិកាវាស់ស្ទង់ថាមពលអគ្គិសនីពីចម្ងាយ នៅលើជើងទម្រក្នុងទូដាក់នាឡិកាវាស់ស្ទង់ថាមពលអគ្គិសនី ។



**02** ដោះគម្របចេញពីនាឡិកាវាស់ស្ទង់ថាមពលអគ្គិសនី (Casborn) ។



**03** វាស់តង់ស្យុងចរន្តឆ្លាស់ លើជើងលេខ 2  និង លើជើងលេខ 11 ដោយប្រើប្រាស់អូមម៉ែត្រ ។




### ⚠ ចំណាំ

- តង់ស្យុងសម្រាប់ដំណើរការឧបករណ៍ត្រួតពិនិត្យនាឡិកាវាស់ស្ទង់ថាមពលអគ្គិសនីពីចម្ងាយ ពីចន្លោះ 60VAC ទៅ 220VAC ។

**04** ភ្ជាប់ខ្សែភ្លើងចរន្តឆ្លាស់ទៅនឹងជើងលេខ 2 និងលើជើងលេខ 11 របស់នាឡិកាវាស់ស្ទង់ថាមពលអគ្គិសនី ។



**05** ដោតខ្សែភ្លើងចរន្តឆ្លាស់ ទៅក្នុងរន្ធ AC ដែលស្ថិតនៅចំហៀងខាងស្តាំ ។




**06** បំពាក់ឧបករណ៍ទាញយកទិន្នន័យ (Infrared) និងឧបករណ៍ការពារពន្លឺរបស់វាទៅលើនាឡិកាវាស់ស្ទង់ថាមពលអគ្គិសនី ។



**07** ភ្ជាប់ខ្សែរបស់ឧបករណ៍ទាញយកទិន្នន័យ (Infrared) ទៅកាន់ឧបករណ៍ត្រួតពិនិត្យនាឡិកាវាស់ស្ទង់ថាមពលអគ្គិសនីពីចម្ងាយ DRC-004G ។




**08** ដំឡើងអង់តែន GSM នៅទីតាំងដែលអាចចាប់សេវាទូរស័ព្ទបានល្អ ។



### ⚠ ចំណាំ

- ទីតាំងអង់តែន GSM ត្រូវតែដាក់នៅទីតាំងដែលអាចទទួលសេវាបានល្អ ។

**09** ភ្ជាប់ខ្សែអង់តែន GSM ទៅកាន់រន្ធ ANT នៅលើឧបករណ៍ត្រួតពិនិត្យនាឡិកាវាស់ស្ទង់ថាមពលអគ្គិសនីពីចម្ងាយ DRC-004G ។




**10** ដំឡើងឧបករណ៍ចាប់សញ្ញាពេលបើកទ្វាជាមួយនិងជើងទម្ររបស់វានៅក្នុងទូនាឡិកាវាស់ស្ទង់ថាមពលអគ្គិសនី ។



### ⚠ ចំណាំ

- ឧបករណ៍ចាប់សញ្ញាពេលបើកទ្វានោះត្រូវដាក់ឱ្យបានត្រឹមត្រូវនៅពេលណាដែលទ្វារបានបិទ ។

**11** ដោតខ្សែឧបករណ៍ទាញយកទិន្នន័យបើកទ្វាក្នុងរន្ធ SW នៅលើឧបករណ៍ត្រួតពិនិត្យនាឡិការវាស់ស្ទង់ថាមពលអគ្គិសនីពីចម្ងាយ DRC-004G ។




**12** ដាក់បញ្ចូលស៊ីមកាត ក្នុងរន្ធដាក់ SIM កាតនៅលើឧបករណ៍ត្រួតពិនិត្យនាឡិការវាស់ស្ទង់ថាមពលអគ្គិសនីពីចម្ងាយ DRC-004G ។




**13** បំពាក់ឧបករណ៍ត្រួតពិនិត្យនាឡិការវាស់ស្ទង់ថាមពលអគ្គិសនីពីចម្ងាយនៅលើជើងទម្ររបស់វានៅក្នុងទូនាឡិការវាស់ស្ទង់ថាមពលអគ្គិសនី ។




**14** បើកកុងតាក់ដើម្បីបើកភ្លើងដំណើរការឧបករណ៍ត្រួតពិនិត្យនាឡិការវាស់ស្ទង់ថាមពលអគ្គិសនីពីចម្ងាយ DRC-004G ។




### ⚠ ចំណាំ

- ឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-004G ដំណើរការធម្មតា Running LED ភ្លឹបភ្លែតៗ រៀងរាល់ ១ វិនាទី ។
- សេវា GSM (GSM Connection) ដែលធ្វើការត្រឹមត្រូវ Net LED ភ្លឹបភ្លែតៗ រៀងរាល់ ៣ វិនាទី ។
- GSM Module ដំណើរការធម្មតា GSM LED ភ្លឺជាប់ ។

sale@vpstart.com | info@vpstart.com (+855) 23 888 167 | (+855) 86 666 677